雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.139

# ប្រទេសចិន-ខេត្តយូនណាន

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 26 លេខ 7533 ថ្ងៃសុក្រ ទី 12 ខែ មករា ឆ្នាំ 2018

## ឡានក្រុងចិនជំរុញការធ្វើទំនើបភាវូបនីយកម្មនៃប្រព័ន្ធគមនាគមន៍សាធារណៈនៅរាជធានីភ្នំពេញ



*ប្រជាពលរដ្ឋកម្ពុជាដែលបាន កំពុងតែប្រើប្រាស់នូវសេវាកម្មដឹក ជញ្ជូនរថយន្តក្រុងយូធុង នៅទីក្រុង ភ្នំពេញ (រូបថតដោយ ស៊ីនហួរ )*

លោកប្រធានអាជ្ញាធរដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញ បានប្រាប់អ្នកកាសែតដោយមានមោទនភាពថា បន្ទាប់ពីប្រើប្រាស់ឡានក្រុងដែលផ្ដល់ដោយប្រទេសចិន នោះចំនួនអ្នកដំណើរ ដែលជិះឡានក្រុងជារៀងរាល់ថ្ងៃ បានកើនឡើងពី ៦.០០០នាក់ដល់ ១,៧ ម៉ឺននាក់ ។ នេះបានបង្ហាញពីការគាំទ្រ និងការពេញចិត្តរបស់អ្នកក្រុងភ្នំពេញ ចំពោះឡានក្រុងរបស់ប្រទេសចិន ។

សព្វថ្ងៃ រាជធានីភ្នំពេញកំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍន៍ដោយមានល្បឿនយ៉ាងលឿន ។ ក្នុងគោលបំណងកែលម្អប្រព័ន្ធគមនាគមន៍សាធារណៈនិងដោះស្រាយបញ្ហាស្ទះចរាចរអង្គភាពនេះបាននាំចូលនូវឡានក្រុងដែលផលិតដោយប្រទេសចិន ។ ឡានក្រុងទាំងនោះបានផ្ដល់ការងាយស្រួលដល់អ្នកក្រុងភ្នំពេញក្នុងការធ្វើដំណើរទៅមក។

ចាប់ពីថ្ងៃទី ១ ខែសីហា ឆ្នាំ ២០១៧ មក ឡានក្រុងម៉ាក "យូធុង" ដែលមានសរសេរអក្សរ "ជំនួយរបស់ប្រទេសចិន" ចំនួន៩៨គ្រឿងត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងរាជធានីភ្នំពេញ ។ ឡានក្រុងដ៏ស្រស់ស្អាតទាំងនោះកំពុងតែធ្វើដំណើរទៅមកជារៀងរាល់ថ្ងៃក្នុងរាជធានីភ្នំពេញ ហើយបាននិងកំពុងផ្ដល់សេវាកម្មដ៏ងាយស្រួលដល់អ្នកក្រុងភ្នំពេញ និងបានបង្កើតជាទេសភាពដ៏ស្អាតទាក់ទាញក្នុងទីក្រុងនេះ ។

ឡានក្រុងរបស់ប្រទេសចិនបានបំពាក់ដោយប្រព័ន្ធម៉ាស៊ីនត្រជាក់ដ៏ជឿនលឿន ហើយមានភាពស្រណុកស្រួល និងមានសុវត្ថិភាពក្នុងការជិះទៅធ្វើដំណើរ ។ ជាពិសេស បន្ទាប់ពីឡានក្រុងចិនត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការមានឡានក្រុងកាន់តែច្រើនត្រូវបានប្រើប្រាស់ជាប្រយោជន៍ដល់អ្នកក្រុង ចំណែករយៈពេលរង់ចាំឡានក្រុងសម្រាប់អ្នកដំណើរក៏បានត្រូវកាត់បន្ថយច្រើនដែរ ។ យើងអាចនិយាយថា ឡានក្រុងចិនបានទាក់ទាញអ្នកដំណើរដ៏ច្រើន ហើយបានធ្វើឱ្យប្រព័ន្ធគមនាគមន៍សាធារណៈនៅរាជធានីភ្នំពេញបង្ហាញរូបភាពទំនើបកម្មដ៏ថ្មីសន្លាង ។

លោក សុវ៉ាគីម ធ្វើការនៅក្នុងក្រុមហ៊ុនពាណិជ្ជកម្ម និងឡូជីស្ទីកមួយ។ លោកបានបញ្ជាក់ថា ផ្ទះខ្ញុំមានចម្ងាយ ១០ គីឡូម៉ែត្រពីកន្លែងធ្វើការរបស់ខ្ញុំ ។ កាលពីមុន ខ្ញុំជិះម៉ូតូទៅធ្វើការរាល់ៗថ្ងៃតាមផ្លូវមានធូលីហុយដ៏ច្រើនហើយហាលថ្ងៃក្ដៅខ្លាំង ។ ដូច្នេះប្រពន្ធខ្ញុំព្រួយចិត្តជាខ្លាំង ។ តែសព្វថ្ងៃខ្ញុំជិះឡានក្រុងដែលផ្ដល់ដោយប្រទេសចិននោះពិតជាមានសុវត្ថិភាព ហើយអាចសំចៃលុយចាក់សាំងទៀត ។

"ស្អាត ត្រជាក់ស្រួល ហើយមានសុវត្ថិភាព"។ នេះគឺជាការវាយតម្លៃរបស់អ្នកដំណើរ ដែលជិះឡានក្រុងរបស់ប្រទេសចិននៅរាជធានីភ្នំពេញ ។ ប៉ុន្តែសម្រាប់តៃកុងឡាន និងអ្នកបញ្ជាប្រព័ន្ធគមនាគមន៍ អ្វីដែលធ្វើឱ្យពួកគេចាប់អារម្មណ៍ជាងគេនោះគឺ "ប្រព័ន្ធវៃឆ្លាត" ដែលត្រូវបានដំឡើងក្នុងឡានក្រុងរបស់ប្រទេសចិន ។

អ្នកបច្ចេកទេសក្នុងបាន បញ្ជាក់ថា ឡានក្រុងនេះបានបំពាក់ដោយ "ប្រព័ន្ធវៃឆ្លាត" ដ៏ជឿនលឿន ។ យើងអាចរកឃើញដោយមានភាពងាយស្រួលនូវព័ត៌មានអំពីទីតាំង ល្បឿន និងផ្លូវធ្វើដំណើររបស់ឡាន ក្រុងលើផែនទីអេឡិចត្រូនិក ។ សូម្បីតែតៃកុងឡានបានជាន់ហ្វ្រាំងប៉ុន្មានដងយើងក៏អាចដឹងច្បាស់ដែរ ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា ដោយសារប្រទេសកម្ពុជាមានអាកាសធាតុក្ដៅខ្លាំង ហើយមានភ្លៀងធ្លាក់ច្រើន អ្នកបច្ចេកទេសចិនបានធ្វើតេស្តសាកល្បងឱ្យឡានក្រុងទាំងនោះហាលភ្លៀង ៤៨ ម៉ោង ដំណើរការក្នុងបរិស្ថានដែលមានកម្ដៅ ១៣០ អង្សាសេ និងឆ្លងកាត់កន្លែងមានទឹក ដើម្បីធានាឱ្យឡានក្រុងទាំងនោះអាចដំណើរការដោយមានភាពប្រក្រតីក្នុងប្រទេសកម្ពុជា ។ ក្រៅពីនេះ "ប្រព័ន្ធវៃឆ្លាត" ដែលបំពាក់ក្នុងឡានក្រុងទាំងនោះបានប្រើប្រាស់បច្ចេកទេសជឿនលឿន ។ ប្រព័ន្ធនេះអាចកត់ត្រានូវទិន្នន័យអំពីទម្លាប់បរឡានរបស់តៃកុងនីមួយៗ ដើម្បីជួយពួកគេលើកកម្ពស់សមត្ថភាពបរឡាន និងថែរក្សាសុវត្ថិភាពរបស់អ្នកដំណើរ ៕

**ដោយ ម៉ាវ ភឹងហ្វី (ស៊ីនហួចិន)**

## ប្រទេស ១៦ បកប្រែ និងបោះពុម្ពផ្សាយសៀវភៅ "ស៊ី ជីនភីង:អភិបាលកិច្ចប្រទេសចិន" [ភាគទី ២]




*សៀវភៅ "ស៊ី ជីនភីង:អភិបាលកិច្ចប្រទេសចិន" ភាគទី២ ជា ភាសាអង់គ្លេសនិងចិន ដែលបាន បោះពុម្ពផ្សាយ កាលពីឆ្នាំទៅ (រូបថតដោយ ស៊ីនហួរ )*

ពេលថ្មីៗនេះ ស្ថាប័នបោះពុម្ពផ្សាយល្បីឈ្មោះនៃប្រទេសចំនួន១៦ និងទីភ្នាក់ងារបោះពុម្ពផ្សាយនៃអាជ្ញាធរភាសាបរទេសចិនបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្ដីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីរួមសហការគ្នាក្នុងការបកប្រែ និងបោះពុម្ពផ្សាយសៀវភៅ "ស៊ី ជីនភីង: អភិបាលកិច្ចប្រទេសចិន" (ភាគទី ២) នៅប្រទេសទាំងនោះ ។

ប្រទេសទាំង១៦រួមមាន ប្រទេសអ៊ីតាលី ប៉ូឡូញ អ៊ុយក្រែន អាល់បានី រូម៉ានី កេនយ៉ា តាហ្ស៊ីគីស្ថាន វៀតណាម បាគីស្ថាន បង់ក្លាដែស កម្ពុជា ឡាវ ម៉ុងហ្គោលី នេប៉ាល់ ស្រីលង្កា និងអាហ្វហ្គានីស្ថាន ។

សៀវភៅ "ស៊ី ជីនភីង: អភិបាលកិច្ចប្រទេសចិន" (ភាគទី ២) កត់ត្រានូវដំណើរអនុវត្ត ដ៏អស្ចារ្យដែលមជ្ឈិមបក្សកុម្មុយនិស្តចិន ដែលដឹកនាំដោយឯកឧត្តម ស៊ី ជីនភីងរួមសាមគ្គីគ្នា និងដឹកនាំសមាជិកបក្សកុម្មុយនិស្តចិនគ្រប់រូប និងប្រជាជនគ្រប់ជនជាតិទូទាំងប្រទេសចិនក្នុងការ ប្រកាន់ខ្ជាប់ និងធ្វើដំណើរតាមមាគ៌ាអភិវឌ្ឍសង្គមនិយមដែលមានលក្ខណៈពិសេសចិនក្នុងយុគសម័យថ្មី ហើយបានបង្ហាញយ៉ាងសព្វគ្រប់អំពីដំណើរវិវឌ្ឍន៍ និងខ្លឹមសារសំខាន់នៃស្មារតីរបស់ឯកឧត្តម ស៊ី ជីនភីង អំពីការកសាងសង្គមនិយមដែលមានលក្ខណៈពិសេសចិនក្នុងយុគសម័យថ្មី ព្រមទាំងក្ដីប្រាថ្នា និងគម្រោងចិន ដែលគណបក្សកុម្មុយនិស្តចិនខិតខំចូលរួមចំណែកក្នុងការស្ថាបនាសហគមន៍រួមវាសនាមនុស្សជាតិ និងបុព្វហេតុនៃការថែរក្សាសន្តិភាពនិងជំរុញការអភិវឌ្ឍរបស់មនុស្សជាតិទាំងមូល ។ សៀវភៅនេះគឺជាឯកសារដ៏សំខាន់ក្រៃលែងសម្រាប់សិក្សារៀនសូត្រ និងស្វែងយល់អំពីស្មារតីរបស់ឯកឧត្តម ស៊ី ជីនភីង អំពីការកសាងសង្គមនិយមដែលមានលក្ខណៈពិសេសចិនក្នុងយុគសម័យថ្មីនិងស្មារតីនៃសមាជបក្សកុម្មុយនិស្តចិនលើកទី១៩ ៕

**(កាសែតប្រជាជន ដេលី)**

## ចិន និងកម្ពុជារួមគ្នាជួយ កុមារខ្មែរដែលមានជំងឺបេះដូងតាំងពីកើត

នៅឆ្នាំ២០១៨ ក្រុមសុខាភិបាលចិន និងក្រសួងសុខាភិបាលកម្ពុជានឹងរួមសហការគ្នាក្នុងការរៀបចំកម្មវិធី "LoveHeartJourney" ដើម្បីជួយព្យាបាលជំងឺដោយឥតគិតថ្លៃឱ្យកុមារខ្មែរដែលមានជំងឺបេះដូងតាំងពីកើត ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលកម្ពុជាបានជួបពិភាក្សាជាមួយលោក យឹន ឆាវតុង ប្រធានផ្នែកវះកាត់នៃមជ្ឈមណ្ឌលព្យាបាលជំងឺបេះដូងតាំងពីកើតក្រុងប៉េកាំងអំពីការរួមគ្នារៀបចំ និងអនុវត្តន៍កម្មវិធី "LoveHeartJourney" នៅប្រទេសកម្ពុជា ។

ឯកឧត្តមរដ្ឋមន្ត្រី ម៉ម ប៊ុនហេង បានមានប្រសាសន៍ថា តាមរយៈកម្មវិធីសប្បុរធម៌នេះ គ្រូពេទ្យចិននឹងជួយវះកាត់ឱ្យកុមារខ្មែរដែលមានជំងឺបេះដូង តាំងពីកើត នៅមន្ទីរពេទ្យ Calmette ក្នុងរាជធានីភ្នំពេញ ។ តាមផែនការដែលបានកំណត់ក្នុងរយៈពេលបីឆ្នាំខាងមុខ ភាគីចិននឹងជួយព្យាបាលជំងឺឱ្យកុមារខ្មែរដែលមានជំងឺបេះដូងតាំងពីកើតយ៉ាងតិច១០០ នាក់ ។ ជាពិសេសបើសិនជាមន្ទីរពេទ្យណាមួយនៅប្រទេសកម្ពុជាមានប្រព័ន្ធសុខាភិបាលពេញលក្ខណៈ គ្រូពេទ្យចិនក៏អាចទៅជួយធ្វើការវះកាត់ឱ្យកុមារដែលមានជំងឺបេះដូងនៅមន្ទីរនោះដែរ។

ក្នុងជំនួបខាងលើនេះ ឯកឧត្តមរដ្ឋមន្ត្រីបានថ្លែងអំណរគុណចំពោះភាគីចិន ដែលបានផ្ដល់ជំនួយឧបត្ថម្ភផ្នែកសុខាភិបាលដ៏ច្រើនដល់ប្រទេសកម្ពុជា ។ ឯកឧត្តមបានបញ្ជាក់ទៀតថា នៅឆ្នាំក្រោយ ប្រទេសចិននឹងផ្ដល់ដល់កម្ពុជានូវរថយន្តសុខាភិបាល៤០គ្រឿង ហើយនឹងជួយកម្ពុជាបណ្ដុះបណ្ដាលគ្រូពេទ្យ ព្រមទាំងសាងសង់អគារសុខាភិបាល និងផ្ដល់គ្រឿងបរិក្ខារសុខាភិបាលដ៏ជឿនលឿនដល់មន្ទីរពេទ្យនៃប្រទេសកម្ពុជា ៕

**ដោយ ហួង យ៉ាវហួ (វេបសាយព័ត៌មានចិន)**

## សូមអញ្ជើញលោកអ្នកមកគយគន់សត្វស្លាបនៅក្រុងសាំងកឹលីឡា



*ក្រុងសាំងកឹលីឡា គឺជា ឋានសួគ៌មួយ សម្រាប់អ្នកនិយមចូលចិត្ត ទស្សនាសត្វស្លាប (រូបថត ដោយChen Fei )*

ពេលថ្មីៗនេះ ទិវាគយគន់សត្វស្លាបអន្តរជាតិក្រុងសាំងកឹលីឡាលើកទី២ បានរៀបចំនៅក្នុងទីក្រុងសាំងកឹលីឡានៃមណ្ឌលឌីឈីងខេត្តយូនណាន ក្រោមប្រធានបទ "អេកូ-ធម្មជាតិមណ្ឌលឌីឈីង ឋានសួគ៌របស់សត្វស្លាប" ។ ទិវាគយគន់សត្វស្លាបនេះត្រូវរៀបចំនៅក្នុងតំបន់ដីសើមណាផាហៃ និងរមណីយដ្ឋានវត្តសុងចានលីន នៅក្នុងក្រុងសាំងកឹលីឡា ។ សកម្មភាពនេះបានបង្ហាញជូនពិភពលោកនូវធនធានធម្មជាតិដ៏សម្បូរ និងល្អប្រសើររបស់ក្រុងសាំងកឹលីឡានៃខេត្តយូនណាន ព្រមទាំងឧត្តមភាព និងតម្លៃនៃការរៀបចំកម្មវិធីអេកូ-ទេសចរណ៍តាមរយៈសកម្មភាពគយគន់សត្វស្លាប ។ សព្វថ្ងៃមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសត្វស្លាបចិនបានកត់ត្រានូវសត្វស្លាបជាង៣០០ប្រភេទ ដែលរស់នៅក្នុងក្រុងសាំងកឹលីឡា ៕

## មជ្ឈមណ្ឌលសហប្រតិបត្តិការសន្តិសុខ និងអនុវត្តន៍ច្បាប់ទន្លេឡានឆាង-មេគង្គសម្ពោធស្លាកនៅក្រុងគុនមីង

ពេលថ្មីៗនេះ ពិធីសម្ពោធស្លាកនៃមជ្ឈមណ្ឌលសហប្រតិបត្តិការសន្តិសុខ និងអនុវត្តន៍ច្បាប់ទន្លេឡានឆាង-មេគង្គបានប្រារព្ធនៅក្នុងទីក្រុងគុនមីងនៃខេត្តយូនណាន ប្រទេសចិន ។ មជ្ឈមណ្ឌលនេះជាអង្គការអន្តរជាតិដែលមានលក្ខណៈអន្តររដ្ឋាភិបាលទី១ ដែលផ្ដោតសំខាន់លើ កិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ និងការអនុវត្តច្បាប់តាមទន្លេឡានឆាង-មេគង្គ ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា តំណាងមកពីភាគីចិននឹងចូលកាន់តំណែងជាអគ្គលេខាធិការអាណត្តិទី១ ចំណែកអគ្គលេខាធិការអាណត្តិក្រោយនឹងចាត់បញ្ជូនដោយផ្លាស់វេនពីបណ្ដាប្រទេសជាសមាជិក ។ មជ្ឈមណ្ឌលនេះនឹងចូលរួមចំណែកក្នុងការបង្ក្រាបបទល្មើសឆ្លងដែន ការផ្លាស់ប្ដូរព័ត៌មាន ការរៀបចំសកម្មភាពអនុវត្តន៍ច្បាប់រួម និងការកសាងសមត្ថភាពអនុវត្តន៍ច្បាប់ ព្រមទាំងផ្ដល់សេវាកម្មដែលមានគុណភាពល្អ និងប្រសិទ្ធភាពខ្ពស់ដល់ស្ថាប័នអនុវត្តន៍ច្បាប់នៃបណ្ដាប្រទេសជាសមាជិក ដោយឈរលើគោលការណ៍ដែលគោរពអធិបតេយ្យភាពនិងច្បាប់បញ្ញត្តិនៃបណ្ដាប្រទេសពាក់ព័ន្ធ ។

បន្ទាប់ពីបង្កើតយន្តការស្ដីពីកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ និងការអនុវត្តច្បាប់តាមទន្លេឡានឆាង-មេគង្គនៅឆ្នាំ២០១១រៀងមក ស្ថាប័នអនុវត្តន៍ច្បាប់នៃបណ្ដាប្រទេសពាក់ព័ន្ធបានរួមគ្នារៀបចំសកម្មភាពអនុវត្តន៍ច្បាប់៦៥លើក និងសកម្មភាពបង្ក្រាបបទល្មើសជួញដូរគ្រឿងញៀន "ផ្លូវនាវាចរណ៍សន្តិសុខ" បួនលើកដែលបានរួមចំណែកក្នុងការថែរក្សាសន្តិសុខតាមផ្លូវនាវាចរណ៍អន្តរជាតិ ទន្លេមេគង្គ និងបានគាំពារសន្តិសុខ និងស្ថិរភាពក្នុងតំបន់ ៕ **ដោយ យឹន យូយហ្វឹង**